ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១០

# សេចក្តីថ្លែងការណ៍

ក្រោយពីបានទទួលសេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយយ៉ាងតក់ក្រហលមក គណបក្សសិទ្ធិមនុស្សបានយកខ្លឹមសារទាំងនោះសួរប្រជាពលរដ្ឋម្ចាស់ឆ្នោតនៅក្នុងមូលដ្ឋានមួយចំនួន ហើយបានទទួលចម្លើយដូចៗគ្នាថាច្បាប់ប្រឆាំងអំពើពុករលួយនេះពុំមានខ្លឹមសារគ្រប់គ្រាន់ ដើម្បីនាំយកជនពុករលួយមកផ្តន្ទាទោសបានឡើយ ។ ថ្ងៃនេះសភាខ្មែរបានអនុម័តសេចក្តីព្រាងច្បាប់នេះដោយអ្នកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សពហិការពុំចូលរួមប្រជុំសម្រេចជាមួយឡើយ ដោយយើងយល់ឃើញថា ច្បាប់នេះមានកង្វះខាតដូចខាងក្រោមនេះ ៖

១. ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និងអង្គភាពប្រឆាំងអំពើពុករលួយគ្មានលក្ខណៈឯករាជ្យ ដូច្នេះពុំអាចបំពេញតួនាទី ភារកិច្ចការងាររបស់ខ្លួនឲ្យមានប្រសិទ្ធភាពបានឡើយ

២. សមាសភាពរបស់ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និងអង្គភាពប្រឆាំងអំពើពុករលួយមានលក្ខណៈច្របូកច្របល់ និងមិនឯករាជ្យ

៣. ថវិកាត្រូវបានកំណត់ដោយរាជរដ្ឋាភិបាល នាំឲ្យគ្មានស្វ័យភាពគ្រប់គ្រាន់ដើម្បីបម្រើការងាររបស់ខ្លួន

៤. អ្នកដែលផ្តល់ព័ត៌មានស្តីពីការប្រព្រឹត្តអំពើពុករលួយរបស់អ្នកនៅក្នុងអំណាចនីតិប្រតិបត្តិ ឬអំណាចនីតិបញ្ញត្តិ និងអំណាចតុលាការ អាចក្លាយជាជនរងគ្រោះទៅវិញ ហើយក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និងអង្គភាពប្រឆាំងអំពើពុករលួយស្ថិតនៅក្រោមអំណាចរបស់រាជរដ្ឋាភិបាល ថាតើពួកគេហ៊ានចោទប្រកាន់ទៅលើជនពុករលួយ ដែលមានឋានៈ និងតួនាទីធំជាងខ្លួនដែរឬទេ ?

៥. ការប្រកាសទ្រព្យសម្បត្តិ ក៏ត្រូវធ្វើជាសម្ងាត់ ផ្ទុយពីគោលការណ៍តម្លាភាព និងអភិបាលកិច្ចល្អ

សរុបមកខ្លឹមសារច្បាប់ប្រឆាំងអំពើពុករលួយនេះទាំងខ្លឹមសារ ទាំងយន្តការ គឺពុំអាចនាំជនពុករលួយមកផ្តន្ទាទោសបានឡើយ តែវាប្រែក្លាយជាឧបករណ៍បង្ក្រាបពលរដ្ឋដែលហ៊ាននិយាយពីមន្ត្រីដែលពុករលួយ និងជាឧបករណ៍សម្រាប់ឲ្យរដ្ឋាភិបាលយកទៅអួតប្រាប់ម្ចាស់អំណោយដើម្បីទទួលបានអំណោយ និងងាយស្រួលខ្ចីលុយបរទេសយកមកធ្វើមានធ្វើបានផ្ទាល់ខ្លួនតែប៉ុណ្ណោះ ។

គណបក្សសិទ្ធិមនុស្ស សូមអំពាវនាវជាថ្មីម្តងទៀត សូមឲ្យអ្នកនយោបាយ និងអ្នកសារព័ត៌មានប្រកាន់យកផលប្រយោជន៍ជាតិ និងប្រជារាស្ត្រយើងជាធំ ។

*សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង*
*ទូរស័ព្ទលេខ ៖ 011 777 750*

Address: #72-74, Street 598, Sangkat Boeung Kok 2, Khan Tuol Kok, Phnom Penh, Cambodia.
Tel: (+855) 17 303 900 / 023 884 649 | Email: hrpcambodia@yahoo.com | Website: www.hrpcambodia.info